សេចក្តីប្រកាសសារព័តមាន

សម្រាប់ការចេញផ្សាយបន្ទាន់

# តំបន់ជីវចម្រុះនៅលើដងទន្លេមេគង្គត្រូវបានចាត់ជាតំបន់សម្រាប់ការគ្រប់គ្រង និងអភិរក្សធនធានជលផល

**ភ្នំពេញ, កម្ពុជា** - ប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ១២៦ប្រក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ និងចុះហត្ថលេខាដោយ **ឯកឧត្តម បណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់ជាផ្លូវការយកតំបន់ដែលអ្នកវិទ្យាសាស្ត្រឲ្យឈ្មោះថា តំបន់ព្រៃលិចទឹកមេគង្គ មានចម្ងាយ ៥៦គីឡូម៉ែត្រ ស្ថិតនៅទីដាច់ស្រយាលលើដងទន្លេមេគង្គ ជាតំបន់សម្រាប់ការគ្រប់គ្រង និងអភិរក្សជីវចម្រុះ និងធនធានជលផល។

តំបន់ព្រៃលិចទឹកមេគង្គនេះមានទីតាំងស្ថិតនៅចន្លោះក្រុងក្រចេះ និងក្រុងស្ទឹងត្រែង នាបែកឦសាននៃប្រទេសកម្ពុជា។ តំបន់នេះមានសំបូរទៅដោយប្រភេទទីជម្រកផ្សេងៗគ្នាជាច្រើនរួមមានបណ្តាព្រៃដែលដុះតាមដងទន្លេ ខ្សែផ្លូវទឹក និងបណ្តុំកោះ ហើយទីជម្រកទាំងអស់នេះគាំទ្រដល់ការរស់នៅរបស់សត្វព្រៃច្រើនប្រភេទ ដែលស្ទើរតែបាត់បង់អស់ទៅហើយពីកន្លែងដ៏ទៃទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ការបង្កើតតំបន់គ្រប់គ្រង និងអភិរក្សជីវចម្រុះជលផលសម្រាប់តំបន់នេះ ផ្តល់នូវឱកាសដ៏ល្អមួយសម្រាប់ការរស់រានរបស់សត្វ និងរុក្ខជាតិជាច្រើនប្រភេទដែលមានសារៈសំខាន់ជាសាកល។

កាលពីដើមឡើយ មិនទាន់មានអ្នកវិទ្យាសាស្ត្រណាបានស្រាវជ្រាវតំបន់ព្រៃលិចទឹកមេគង្គនេះឡើយ រហូតមកទល់ឆ្នាំ២០០៦និង២០០៧ ទើបមានក្រុមអ្នកវិទ្យាសាស្ត្រនៃរដ្ឋបាលជលផល និងរដ្ឋបាលព្រៃឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងក្រុមអ្នកវិទ្យាសាស្ត្រនៃអង្គការ WWF បានចុះសិក្សាអំពីតំបន់នេះ។ តំបន់ព្រៃលិចទឹកមេគង្គគាំទ្រដល់ការរស់នៅរបស់សត្វផ្សោតទន្លេមេគង្គ ដែលជាប្រភេទសត្វទទួលរងគ្រោះថ្នាក់បំផុតអាចឈានទៅរកភាពផុតពូជ សត្វកន្ធាយក្បាលកង្កែបដ៏កម្រ ជាសត្វដែលអ្នកវិទ្យាសាស្ត្រធ្លាប់បានសន្មត់ថាវាបានផុតពូជពីតំបន់មេគង្គទាំងមូលទៅហើយ។ តំបន់ព្រៃលិចទឹកមេគង្គក៏ជាទីជម្រកដ៏សំខាន់ សម្រាប់សត្វស្លាបចង្កំកស ដែលជាហ្វូងមានចំនួនច្រើនជាងគេលំដាប់ទីបីនៅទូទាំងប្រទេសកម្ពុជា។ ក្រុមអ្នកវិទ្យាសាស្ត្រក៏បានកត់ត្រាទុកផងដែរនូវប្រភេទរុក្ខជាតិម្យ៉ាងដែលមានឈ្មោះវិទ្យាសាស្ត្រថា *Amorphophallus sp.* ជារុក្ខជាតិដែលមានតែមួយគត់នៅលើសាកលលោក ហើយវាក៏ជាកំណត់ត្រាថ្មីសម្រាប់ពិភពលោកផងដែរ។ ក្រៅពីនេះ ប្រភេទ រុក្ខជាតិ ត្រី និង ឧរង្គសត្វដ៏កម្រ ដែលជាកំណត់ត្រាថ្មីសម្រាប់កម្ពុជាក៏ត្រូវបានគេកត់ត្រាទុកផងដែរ។

ឯកឧត្តមបណ្ឌិត **ណៅ ធូក** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកប្រធានរដ្ឋបាលជលផលបានមានប្រសាសន៍ថា៖ “រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់នូវតម្លៃជីវចម្រុះនៃតំបន់ព្រៃលិចទឹកមេគង្គ ព្រមទាំងសេចក្តីត្រូវការចាំបាច់ក្នុងការការពារធនធានទាំងនេះសម្រាប់ជាប្រយោជន៍យូរអង្វែង។ ប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនេះ នឹងជួយពង្រឹងកិច្ចការពារតំបន់ដ៏មានសារៈសំខាន់នេះឲ្យកាន់តែប្រសើរឡើង។”

ឯកឧត្តម **ណៅ ធូក** បានមានប្រសាសន៍បន្ថែមទៀតថា៖ “តំបន់ជីវចម្រុះ និងធនធានធម្មជាតិនេះជាមរតកដ៏ពិសិដ្ឋរបស់ប្រទេសកម្ពុជា ហើយខ្ញុំជឿជាក់ថាការបង្កើតជាតំបន់គ្រប់គ្រង និងអភិរក្សជីវចម្រុះជលផលសម្រាប់

តំបន់នេះ ជាការរួមចំណែកមួយផ្នែកធំដល់ការថែរក្សាប្រព័ន្ធអេកូឡូស៊ីជីវចម្រុះឲ្យគង់វង្ស និងចូលរួមលើកស្ទួយការប្រើប្រាស់ប្រកបដោយនិរន្តរភាពរបស់សហគមន៍មូលដ្ឋាននូវធនធាននៅក្នុងតំបន់នេះ។”

ក្រោយពេលក្រុមអ្នកវិទ្យាសាស្រ្តបានបញ្ចប់ការស្រាវជ្រាវនៅក្នុងឆ្នាំ២០០៦និង២០០៧រួចរាល់ វិធានការសម្រាប់ការងារអភិរក្សត្រូវបានបង្កើតឡើង។ ស្ថាប័នជំនាញៗដែលពាក់ព័ន្ធនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គការ WWF និងស្ថាប័នជាដៃគូដ៏ទៃទៀត បាន និងកំពុងអនុវត្តកម្មវិធី និងសកម្មភាពការងារផ្សេងៗ ដើម្បីជួយភ្នាក់ងារថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានក្នុងការងារគ្រប់គ្រងតំបន់ឲ្យមានប្រសិទ្ធិភាព ក្នុងនោះរួមមានការកសាងសមត្ថភាព ការងារផ្សព្វផ្សាយនិងអប់រំដល់ប្រជាជនសហគមន៍ដែលរស់នៅជាប់នឹងតំបន់ជីវចម្រុះ ការអភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិតរបស់ប្រជាជនដើម្បីធានាការប្រើប្រាស់ និងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនូវធនធានសំខាន់ៗ ជាពិសេសធនធានត្រី និងធនធានព្រៃឈើសម្រាប់ប្រជាជនមូលដ្ឋាន។ ថ្វីបើមានការខិតខំប្រឹងប្រែងក្នុងការការពារយ៉ាងនេះក្តី សកម្មភាពឃាយីពីសំណាក់មនុស្សដែលកើនឡើងជាប្រចាំកំពុងដាក់សម្ពាធលើតំបន់ព្រៃលិចទឹកមេគង្គ និងសត្វព្រៃនានាដែលរស់នៅទីនោះ។ កត្តាគំរាមកំហែងរួមមានការធ្វើដីសម្បទានដែលនាំឲ្យឈានទៅដល់ការកាប់បំផ្លាញព្រៃឈើ ការនេសាទដោយប្រើឧបករណ៍ដែលបណ្តាលឲ្យហិនហោចធនធាន និងការរុករករ៉ែទាំងនៅក្នុងតំបន់ដីគោក និងតំបន់ដីកោះលើដងទន្លេមេគង្គ ដែលវាជាកត្តាបំផ្លាញទីជម្រក។

កញ្ញា **មីហ្សែល អូរិន** នាយកស្តីទីនៃអង្គការ WWF បាននិយាយថា៖ “ប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនេះ ផ្តល់នូវក្របខ័ណ្ឌច្បាប់ដ៏សំខាន់មួយសម្រាប់គម្រោងអភិរក្សនានា ដែលកំពុងមានដំណើរការនៅក្នុងតំបន់ព្រៃលិចទឹកមេគង្គ។” កញ្ញា **មីហ្សែល អូរិន** បានពន្យល់បន្ថែមទៀតថា៖ “ប្រកាសនេះផ្តល់នូវសិទ្ធិក្នុងក្របខ័ណ្ឌច្បាប់ដល់អាជ្ញាធរថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ព្រមទាំងស្ថាប័នជាដៃគូតួយ៉ាងអង្គការ WWF ដែលកំពុងអនុវត្តការងារដើម្បីជ្រោមជ្រែងដល់ការអភិរក្សនៅក្នុងតំបន់ ក្នុងការចាត់វិធានការចំពោះសកម្មភាពគំរាមកំហែងផ្សេងៗនាពេលបច្ចុប្បន្ន និងនាពេលអនាគត ដែលឃាយីដល់ជីវចម្រុះនៅក្នុងតំបន់ ព្រមទាំងពង្រឹងការងារអភិរក្សដែលកំពុងមានដំណើរការឲ្យកាន់តែមានប្រសិទ្ធិភាពថែមទៀត ដោយក្នុងនោះដែរគឺការបន្តលើកទឹកចិត្តប្រជាជនមូលដ្ឋានឲ្យចូលរួមក្នុងសកម្មភាពអភិរក្ស។”

ដើម្បីអនុវត្តខ្លឹមសារដែលមានចែងក្នុងប្រកាស មន្រ្តីជំនាញពាក់ព័ន្ធនៃរដ្ឋបាលជលផល និងបុគ្គលិកនៃអង្គការ WWF នឹងសហការគ្នាដើម្បីកសាងឡើងនូវផែនការលម្អិតមួយ សម្រាប់ការគ្រប់គ្រងសកម្មភាពការងារអភិរក្សយូរអង្វែង ដើម្បីការពារតំបន់ទីម្រក និងសត្វព្រៃ។

**សម្រាប់ពត៌មានបន្ថែម សូមទាក់ទង៖**


លោក ទេព អស្នារិទ្ធ
ប្រធានផ្នែកសារពត៌មាន និងកិច្ចការសាធារណៈ
WWF កម្ពុជា

ទូរស័ព្ទលេខ: +855 (0) ២៣ ២១៨ ០៣៤
អ៊ីម៉ែល: asnarz@gmail.com & asnarith.tep@wwf.panda.org